# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

## រវាង

## រោងចក្រ ខេវីធី អ៊ីអិមប៊ី បេស(ខេមបូឌា)ឯ.ក

## ជាមួយតំណាងកម្មករនិយោជិតទាំងអស់

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ៨ និង ០០នាទីព្រឹក នៅក្នុងរោងចក្រ ខេវីធី អ៊ីអិមប៊ី បេស(ខេមបូឌា)ឯ.ក មានកិច្ចប្រជុំមួយរវាងរដ្ឋបាល និង តំណាងកម្មករនិយោជិតចំនួន ២១នាក់។ នៅអង្គប្រជុំនេះប្រធានរដ្ឋបាលបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានការបច្ចុប្បន្នដែលបណ្តាលមកពីការថមថយច្រវាក់ផលិតកម្មក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចសកលធ្វើអោយប៉ះពាល់ដល់រោងចក្រ។ហេតុដូចនេះក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ២៣នាក់ (ស្រី១៦) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២៧នាក់ (ស្រី១៨) រយៈពេល៦១ថ្ងៃ ដោយមានការព្រមព្រៀងពីតំណាងកម្មករនិយោជិត គិតចាប់ពីថ្ងៃទី ២១ខែមិថុនា ឆ្នាំ២០២៣ ដល់ថ្ងៃទី ២០ខែសីហា ឆ្នាំ២០២៣។

កម្មករនិយោជិតទទួលបានអត្ថប្រយោជន៍និងការទូទាត់ដូចតទៅ៖

- ទទួលបានប្រាក់ឧបត្ថម្ភ ៧៥ ដុល្លារអាមេរិច ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ ដោយបើកជូនរៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ៨ និង ៥០នាទី ព្រឹកនៅថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

រាជធានីភ្នំពេញថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

ស្នាមមេដៃតំណាងកម្មករនិយោជិតទាំងអស់





ហត្ថលេខា និង ត្រាក្រុមហ៊ុន

នាយកក្រុមហ៊ុន